# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០៩នាក់ និងរកឃើញវិជ្ជមានកូវីដ១៩ ថ្មី ០១នាក់

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

– អ្នកព្យាបាលជាសះស្បើយ សរុបចំនួនកើនដល់ ៣៤នាក់ (ស្មើនឹង ៣០,៩១% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ០៣នាក់ ស្ត្រីជនជាតិបារាំង ០៥នាក់ និងបុរសជនជាតិខ្មែរ ២១នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)

– អ្នកដែលកំពុងសម្រាកព្យាបាល បានថយចុះមកនៅសរុបចំនួន ៧៦នាក់ (ស្ត្រី ២៣នាក់ និងបុរស ៥៣នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១១០នាក់ (ស្ត្រី ៣០នាក់ និងបុរស ៨០នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០៩នាក់ ដូចខាងក្រោម (ជនជាតិខ្មែរ ០១នាក់ នៅខេត្តសៀមរាប ជនជាតិបែលហ្ស៊ិក ០១នាក់ នៅរាជធានីភ្នំពេញ និងជនជាតិបារាំង ០៧នាក់ នៅខេត្តព្រះសីហនុ)៖

– បុរសជនជាតិខ្មែរអាយុ ៤០ឆ្នាំ មានទីលំនៅនៅខេត្តសៀមរាប ដែលបានវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីនៅមន្ទីរពេទ្យខេត្តសៀមរាប ។

– បុរសអាយុ ៣៣ឆ្នាំ ជនជាតិបែលហ្ស៊ិក នៅរាជធានីភ្នំពេញ ព្យាបាលបានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

– បុរសជនជាតិបារាំង អាយុ ៥២ឆ្នាំ និង ៦៦ឆ្នាំ ព្រមទាំងស្ត្រីជនជាតិបារាំង អាយុ ៥៩ឆ្នាំ ៦១ឆ្នាំ ៦២ឆ្នាំ ៦៣ឆ្នាំ និង៦៩ឆ្នាំ ជាអ្នកទេសចរនៅខេត្តព្រះសីហនុ ត្រូវបានព្យាបាលជាសះស្បើយដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក និងត្រូវបានអនុញ្ញាតឲ្យចេញពីកន្លែង

ព្យាបាលក្នុងសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ ដើម្បីរងចាំការវិលត្រឡប់ទៅប្រទេសបារាំងវិញ។ ជាបណ្ដោះអាសន្ន ពួកគាត់ត្រូវបំបែកចេញពីជាន់ព្យាបាលមួយនៃសណ្ឋាគារមួយដែលដាក់អ្នកមានវីរុសកូវីដ១៩ នៅតាមបន្ទប់ដាច់ដោយឡែកៗពីគ្នា ឲ្យមកស្នាក់នៅជាន់មួយទៀត តាមបន្ទប់ៗដាច់ដោយឡែកពីគ្នាដែរ ដែលជាជាន់សម្រាប់អ្នកព្យាបាលជាសះស្បើយ។

**៣. ករណី ទី២ មានវីរុសកូវីដ ១៩ ថ្មី** នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ មានចំនួន ០១នាក់ ៖

បុរសជនជាតិខ្មែរ អាយុ ៥៨ឆ្នាំ (រស់នៅក្នុងសណ្ឋាគារមួយនៃខេត្តព្រះសីហនុ) វិជ្ជមានវីរុសកូវីដ ១៩ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ។ បុរសរូបនេះ ជាអ្នកគ្រប់គ្រង និងធ្វើបដិសណ្ឋារកិច្ចដោយផ្ទាល់ជាមួយភ្ញៀវទេសចរបារាំងទាំងអស់នោះ និងជាអ្នកប៉ះពាល់ផ្ទាល់ជាមួយអ្នកទេសចរបារាំងមានវីរុសកូវីដ១៩ ដែលបានរកឃើញនៅក្រុងព្រះសីហនុ។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០